# អំពីបទចម្រៀង ៖ "សាវតារខ្មែរ"

## ដោយ បណ្ឌិតសភាចារ្យ សោម សុមុនី

## ១. ស្នាដៃដើម

បទចម្រៀង "**សាវតារខ្មែរ**" ជាចម្រៀងមួយបទ ក្នុងចំណោមកម្រងចម្រៀង១៣បទ ក្នុងសៀវភៅ "**កម្រងសិល្បៈសិក្សា**" ជាប្រភេទសៀវភៅអប់រំតាមរយៈសិល្បៈ ចម្រៀង របាំ ជាស្នាដៃដែលបានចងក្រងឡើងដោយលោក **ឡុង ភុន** ក្នុងអម្លុងឆ្នាំ១៩៥៨ ដែលកាលនោះ លោកជាគ្រូបង្រៀន ធ្វើការនៅមន្ទីរចាត់ការនៃក្រសួងគរុកោសល្យ នៅភ្នំពេញ។ តាមការបញ្ជាក់របស់លោក **ឡុង ភុន** បទចម្រៀងទាំងនោះ (គឺរួមទាំងបទ "សាវតារខ្មែរ" ដែលជាកម្មវត្ថុនៃការសិក្សារបស់យើង) មានលោក **លី គឹមអួច** និងលោក **ឌីណាស្សុ** ហៅ **សែម** ជាអ្នកនិពន្ធអក្សរភ្លេង ឯទំនុកច្រៀងគឺនិពន្ធដោយលោក **ហាស៊ុ ចន់ហាក់**។

សៀវភៅដែលមានចំណងជើងថា "**កម្រងសិល្បៈសិក្សា**" ដែលលោក **ឡុង ភុន** បានចងក្រង ត្រូវបានក្រសួងសិក្សាធិការជាតិ នៃព្រះរាជអាណាចក្រកម្ពុជា ចេញប្រកាសសម្រេចឱ្យបញ្ចូលទៅក្នុងពពួកសៀវភៅនិងការផ្សាយខាងការសិក្សា និងបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងសាលារៀនសាធារណៈទូទៅក្នុងប្រទេស តាមរយៈប្រកាស លេខ៤៧៨៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៥៨ ចុះហត្ថលេខាដោយអ្នកឧកញ៉ា **ទៅ សេង** រដ្ឋលេខាធិការក្រសួងសិក្សាធិការជាតិ។

ក្នុងសៀវភៅ "**កម្រងសិល្បៈសិក្សា**" រួមមានចម្រៀងអប់រំចំនួន១៣បទ គឺបទ៖ (១) យើងទៅសាលារៀន (២) សារិកាវីករាយ (៣) បុកស្រូវសម័យ (៤) ដំណើរយុវជន (៥) ឱផ្ទៃស្រុកខ្មែរ (៦) អុំទូក (៧) សង្គ្រាមស្នេហាជាតិ (៨) សាវតារខ្មែរ (៩) សុរិយាល្ងាចថ្ងៃ (១០) បំពេ (១១) មិត្តភាពយុវនារី (១២) លាហើយណារី និង(១៣) បទ ប្រវត្តិសាស្ត្រខ្មែរ។ ចំពោះបទនិមួយៗមានទំព័រអក្សរភ្លេង ទំព័រទំនុកច្រៀង និងមានសេចក្តីណែនាំអំពីប្រភពបទ ប្រភេទបទ និងរបៀបសំដែងចំពោះបទណាដែលអាចសំដែងបាន។

ក្នុងលំនាំដើមនៃស្នាដៃនេះ លោក **ឡុង ភុន** បានបញ្ជាក់ពីគុណប្រយោជន៍ដែលសិស្សអាចទទួលបានពីការសិក្សាសិល្បៈ គឺការសិក្សាសិល្បៈជាជំនួយបណ្តុះកុមារទាំងខាងផ្លូវកាយ ផ្លូវចិត្ត និងគំនិត។ ជាពិសេសទៅទៀតនោះ គឺលោកបានណែនាំអំពីគោលការណ៍នៃការសិក្សាសិល្បៈ ពីរបៀបបង្រៀន ពីបទបច្ចេកទេសខាងច្រៀង និងពីអក្សរភ្លេង ជាការងាយស្រួលដល់អ្នកសិក្សាថែមទៀតផង។

ឃើញថា បទចម្រៀង "**សាវតារខ្មែរ**" ត្រូវបានបញ្ជ្រាបក្នុងបេះដូងកូនខ្មែរជាច្រើន តាមការអប់រំតាមសាលារៀន និងការរៀនច្រៀងតាមគ្នានៅក្រៅសាលា តាំងពីឆ្នាំ១៩៥៩មក ក្នុងរយៈពេលជាច្រើនឆ្នាំ មុនពេលដែលមាតុភូមិយើងជួបនឹងភាពខ្ទេចខ្ទាំ ដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ ជាច្រើនទសវត្សរ៍។

### បទ ៖ សាវតារខ្មែរ

១- ខ្មែរអើយចូរចាំជាក់ថា តាមសាវតារជាតិខេមរាធ្លាប់តែថ្កើង ទឹកដីខ្មែរធំ ទូលំទូលាយ
សព្វសាយរុងរឿង គេឯងតែងលើកដំកើង ដំកល់ជាតិយើង ចាត់ទុកឡើងជាជាតិច្បង។
២- អារ្យធម៌ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សាយផ្សាយ គ្រប់ទិសទាំងឡាយចុងបូព៌ា សាសនា

សិល្បៈ ចម្លាក់វិចិត្រ គំនិតសិក្សា តន្ត្រី ទស្សនវិជ្ជា យុទ្ធសាស្ត្រ ជាគោលការណ៍ខ្មែរផ្សាយទៅ។
៣- ខ្មែរអើយចូរស្តាប់សាវតារ ដែលបានចរចា បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង តាំងចិត្តឲ្យធំ
ខិតខំប្រឹងវិញ បញ្ចេញដំកើង តម្លៃនៃជាតិយើង ឲ្យបានរុងរឿង ជាថ្មីឡើងតាមសាវតារ។
( *ចម្លងតាមច្បាប់ដើមដោយរក្សាទាំងអក្ខរាវិរុទ្ធមួយចំនួនតាមសំណេរសម័យនោះ*)

## ២. ការផ្សព្វផ្សាយឡើងវិញ

គ្រាដែលប្រជាជាតិយើងបានរស់រាន រួមរស់ជាថ្មីក្នុងមហាគ្រួសារខ្មែរ ក្នុងសុខសិរី សុខសន្តិភាព និង អភិវឌ្ឍនភាព ដោយគុណ៧មករា ដែលមានសម្តេចទាំងបីជាប្រមុខដឹកនាំប្រកបដោយគតិបណ្ឌិត យើងឃើញ មានក្រសួង ស្ថាប័ននានា ដែលមានឆន្ទៈក្នុងការបណ្តុះស្មារតីស្នេហាជាតិ តាមរយៈសិល្បៈសិក្សា បានផ្សព្វផ្សាយ បទចម្រៀង "**សាវតារខ្មែរ**" នេះយ៉ាងលាន់ឮឡើងវិញ។ តែយើងសង្កេតឃើញមានចំណុចខុសគ្នាជាច្រើន ទាំង សំណេរខុសគ្នា ការប្រើពាក្យខុសគ្នា និងឃ្លាប្រយោគខុសគ្នា ក្នុងបទចម្រៀង "**សាវតារខ្មែរ**" ដែលមានប្រភពតែ មួយ និងដែលត្រូវបាននិងកំពុងផ្សព្វផ្សាយដោយអង្គភាពនិងស្ថាប័នផ្សេងៗគ្នា បច្ចុប្បន្ននេះ។

អត្ថបទដែលមានចំណុចខុសពីស្នាដៃដើម និងខុសគ្នាដោយអន្លើនេះ មានជាអាទិ៍៖

**(១)**- អត្ថបទក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៦ បោះពុម្ពដោយក្រសួងអប់រំ យុវជន និង កីឡា តាម ប្រកាសលេខ ៤៣៨អយក.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៦ រៀបចំដោយអ្នកនិពន្ធមួយក្រុម។ អត្ថបទ នោះត្រូវបាននិងកំពុងបង្រៀនតាមសាលារៀនសាធារណៈរហូតដល់សព្វថ្ងៃ។

**(២)**- អត្ថបទដែលផ្សព្វផ្សាយតាមវិទ្យុជាតិបច្ចុប្បន្ន។

**(៣)**- អត្ថបទជាការផ្សាយដោយសាលាក្រុងភ្នំពេញ ដែលមានបញ្ជាក់ថា ជាព្រះរាជនិពន្ធ របស់សម្តេច ព្រះសង្ឃរាជ **ជួន ណាត**។

ដោយឃើញមានភាពខុសគ្នាដូចនេះ កាសែតរស្មីកម្ពុជា ចុះផ្សាយថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៨ ក៏បាន បង្ហាញអត្ថបទដែលមានចំណុចខុសគ្នាទាំងនោះ រួមនឹងយោបល់ឯកឧត្តម **ជុច គឿន** រដ្ឋលេខាធិការក្រសួង វប្បធម៌ជុំវិញបញ្ហានេះ ដែលលើកឡើងថា ដោយសារការអភិវឌ្ឍរបស់ប្រទេស អត្ថបទក្រោយៗ វាមានការកែប្រែ ខ្លះខាងទិដ្ឋភាពអក្សរសាស្ត្រ ប៉ុន្តែអត្ថន័យដូចគ្នាទេ។

ក្រោយការចុះផ្សាយរបស់កាសែតរស្មីកម្ពុជា នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ នៃក្រសួងអប់រំ យុវជន និងកីឡា ក៏បានចេញលិខិតមួយ លេខៈ២៤២ សគ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ជូនព័ត៌មានស្តីពីប្រតិកម្ម របស់កាសែតរស្មីកម្ពុជាចំពោះការផ្សព្វផ្សាយបទចម្រៀង "**ពង្សាវតារខ្មែរ**" ដែលមានចំណុចខុសៗគ្នានេះ ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និងស្នើសុំអនុសាសន៍ ដោយបានបញ្ជាក់ពីជំហររបស់ខ្លួនថា គួររក្សា អត្ថន័យដើមនៃបទចម្រៀងដែលមានអ្នកនិពន្ធច្បាស់លាស់ ព្រោះវាមានអត្ថន័យជ្រាលជ្រៅជាងអត្ថបទផ្សេង ទៀតទាំងអស់។

## ៣. ចំណុចខុសគ្នាក្នុងបទចម្រៀងច្បាប់ដើម និងក្រោយ

ពិនិត្យទំនុកច្រៀងនៃ បទ "**សាវតារខ្មែរ**" ដែលនិពន្ធដោយលោក **ហង្ស ចន់ហាក់** និងខ្លឹមសារផ្សព្វ ផ្សាយបច្ចុប្បន្ន យើងឃើញមានភាពខុសគ្នាប្រាំពីរចំណុចដូចខាងក្រោម ៖

**- ចំណុចខុសគ្នាទី១** (ចំណងជើង)

- អត្ថបទរបស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ ថា៖ "**សាវតារខ្មែរ**"

- អត្ថបទទាំងបីបច្ចុប្បន្ន ថា៖ "**ពង្សាវតារខ្មែរ**"

(តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យ ***ពង្សាវតារ*** ជាមេពាក្យ ហើយមានន័យពេញលេញតាមវចនស័ព្ទ ឯពាក្យ ***សាវតារ*** ជាពាក្យដែលសរសេរឲ្យខ្លី ហើយគ្រាន់តែអាចប្រើបាន)

**- ចំណុចខុសគ្នាទី២** (ក្នុងខ្លឹមសារវគ្គទីមួយ)

- អត្ថបទឆ្នាំ១៩៥៨ និងអត្ថបទផ្សាយដោយសាលាក្រុងភ្នំពេញ ថា៖ "**តាមសាវតារ ជាតិខេមរា ធ្លាប់តែថ្កើង**"

- សៀវភៅសិក្សាសង្គមថ្នាក់ទី៦ ឆ្នាំ១៩៩៦ ថា៖ "**តាមពង្សាវតារ បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង**"

- អត្ថបទតាមវិទ្យុជាតិបច្ចុប្បន្ន ថា៖ "**តាមពង្សាវតារ ជាតិខេមរា ធ្លាប់តែថ្កើង**"

**- ចំណុចខុសគ្នាទី៣** (ក្នុងខ្លឹមសារវគ្គទីមួយ)

- អត្ថបទឆ្នាំ១៩៥៨ អត្ថបទក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៦ និង អត្ថបទផ្សាយដោយសាលាក្រុងភ្នំពេញ ថា៖ "**សព្វសាយ**រុងរឿង"

- អត្ថបទផ្សព្វផ្សាយតាមវិទ្យុជាតិបច្ចុប្បន្ន ថា៖ "**ផ្សព្វផ្សាយ**រុងរឿង"

**- ចំណុចខុសគ្នាទី៤** (ក្នុងខ្លឹមសារវគ្គទីពីរ)

- អត្ថបទក្រសួងសិក្សាធិការជាតិឆ្នាំ១៩៥៨ ថា៖ "បានចេញ**ផ្សាចផ្សាយ**"

- អត្ថបទទាំងបីបច្ចុប្បន្ន ថា៖ "បានចេញ**ផ្សព្វផ្សាយ**"

**- ចំណុចខុសគ្នាទី៥** (ក្នុងខ្លឹមសារវគ្គទីពីរ)

- អត្ថបទរបស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ ថា៖ "**យុទ្ធសាស្ត្រ**"

- ក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៦ ឆ្នាំ១៩៩៦ ថា៖ "**អាចយកសិក្សា**"

- តាមវិទ្យុជាតិបច្ចុប្បន្ន និងអត្ថបទផ្សាយដោយសាលាក្រុងភ្នំពេញ ថា៖ "**ព្រះពុទ្ធសាសនា**"

**- ចំណុចខុសគ្នាទី៦** (ក្នុងខ្លឹមសារវគ្គទីបី)

- អត្ថបទឆ្នាំ១៩៥៨ និងសៀវភៅសិក្សាសង្គមថ្នាក់ទី៦ ឆ្នាំ១៩៩៦ ថា៖ "តាំងចិត្ត**ឲ្យធំ**"

- តាមវិទ្យុជាតិបច្ចុប្បន្ន និងអត្ថបទផ្សាយដោយសាលាក្រុងភ្នំពេញ ថា៖ "តាំងចិត្ត**ឲ្យមាំ**"

**- ចំណុចខុសគ្នាទី៧** (ក្នុងខ្លឹមសារវគ្គទីបី)

- អត្ថបទក្រសួងសិក្សាធិការជាតិឆ្នាំ១៩៥៨ ៖ "**បញ្ចេញដំកើងតម្លៃនៃជាតិយើង**"

- សៀវភៅសិក្សាសង្គមថ្នាក់ទី៦ ៖"**បញ្ចេញតំកើងតំលៃនៃជាតិខ្មែរយើង**"

- តាមវិទ្យុជាតិបច្ចុប្បន្ន ៖ "**សាមគ្គីជាតិយើង ក្នុងចិត្តតំកើង តំលៃខ្មែរយើង**"

- អត្ថបទសាលាក្រុងភ្នំពេញ ៖ "**សាមគ្គីជាតិយើង ក្នុងចិត្តតម្កើង តម្លៃខ្មែរយើង**"

## ៥. ការពិចារណាលើអត្ថបទទាំងបួន

១- ស្នាដៃដើមបំផុតគឺអត្ថបទដែលផ្សាយក្នុងសៀវភៅ "**កម្រងសិល្បៈសិក្សា**" របស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨។ យើងរកបានឯកសារជាច្បាប់ដើម ដែលក្នុងនោះមិនមែនមានតែបទ "**សាវតារខ្មែរ**" តែប៉ុណ្ណោះទេ តែមានបទចម្រៀងដែលមានអត្ថន័យអប់រំ និងមានខ្លឹមសារបណ្ដុះស្មារតីស្នេហាជាតិ ជាច្រើនទៀត មានទាំងអក្សរភ្លេង មានទាំងទំនុកច្រៀង មានទាំងសេចក្តីណែនាំ អំពីរបៀបច្រៀង ចាត់ទុកថាជាឯកសារមានតម្លៃ។

ឯអត្ថបទផ្សេងទៀត គ្រាន់តែជាអត្ថបទកែសម្រួល និងចម្លងតាម ដែលអត្ថបទខ្លះ កែពីល្អត្រឹមត្រូវតាមសិល្បៈតែងនិពន្ធ ទៅជាមិនសូវល្អ ហើយអត្ថបទខ្លះទៀត គ្រាន់តែចម្លងតាម ក៏ចម្លងមិនត្រឹមត្រូវផង។ នេះអាចដោយសារ អ្នកផ្សព្វផ្សាយឡើងវិញនោះ គ្រាន់តែមានឆន្ទៈចង់រក្សា ប៉ុន្តែដោយគ្មានឯកសារដើម ក៏សរសេរឡើងវិញតាមការចងចាំ ឬអាចដោយគ្មានឯកសារដើម ក៏បន្ថែមបន្ថយតាមការចូលចិត្តរបស់ខ្លួន ដែលនេះវាខុសពីសីលធម៌ក្នុងបរិបទកម្មសិទ្ធិបញ្ញា។

**២-** អត្ថបទរបស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ មានបញ្ជាក់ច្បាស់លាស់អំពី ឈ្មោះអ្នកសរសេរបទភ្លេងគឺ លោក **លី ឥមអួច** និង លោក **ឌីណាស្ស៊ុ** ហៅ **សែម** ឈ្មោះអ្នកសរសេរទំនុកច្រៀងគឺ លោក **ហាច្យ ឆន់ហាក់** និងអ្នកចងក្រងជាសៀវភៅ ឈ្មោះ សៀវភៅ "**កម្រងសិល្បៈសិក្សា**" គឺ លោក **ឡូន កន**។ នេះជានិម្មិតកម្មពិតប្រាកដ ដែលត្រូវទទួលស្គាល់ ទោះមានកំហុសឆ្គងតិចឬច្រើនក្តី។ ឯអត្ថបទផ្សេងទៀត គ្មានការបញ្ជាក់ច្បាស់លាស់ គឺគ្រាន់តែជាស្នាដៃកែសម្រួល មិនអាចចាត់ទុកជានិម្មិតកម្មបានឡើយ ទោះល្អឬមិនល្អជាងស្នាដៃដើមក៏ដោយ។

**៣-** អត្ថបទរបស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ និង អត្ថបទផ្សាយដោយសាលាក្រុងភ្នំពេញដែលមានបញ្ជាក់ថា ជាព្រះរាជនិពន្ធ របស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** មានសំណេរត្រឹមត្រូវភាគច្រើនតាមគោលការណ៍បច្ចុប្បន្ន គឺយកតាមសំណេរក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ក៏ប៉ុន្តែក៏នៅមានសំណេរតិចតួចដែលគួរសម្រួល (សូមពិនិត្យអត្ថបទច្បាប់ដើម)។

ឯ អត្ថបទក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៦ បោះពុម្ពដោយក្រសួងអប់រំ យុវជន និង កីឡា តាមប្រកាសលេខ ៤៣៨អយក.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៦ គឺប្រើព្យាង្គរាយ តាមក្បួនទំនាញសូរដែលអនុវត្តដោយក្រសួងតាំងពីឆ្នាំ១៩៧៩ មក។

**៤-** ចំពោះការប្រើពាក្យ ក្នុងអត្ថបទក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ ពាក្យនិមួយៗមានន័យជ្រាលជ្រៅ ច្បាស់លាស់ស្របតាមគំនិតសំខាន់របស់អត្ថបទ ឯក្នុងអត្ថបទផ្សេងទៀត ដែលមានការកែសម្រួលដោយចេតនា (ឬ អាចដោយសារអ្នកផ្សព្វផ្សាយនោះគ្មានឯកសារដើម ហើយចងចាំមិនអស់ ក៏តាក់តែងថែមដោយខ្លួនឯង) ពាក្យដែលបានប្តូរនោះ ខ្លះក៏មានភាពច្រំដែល និងខ្លះក៏គ្មានន័យអ្វីសំខាន់។ រីឯការតែងឃ្លាប្រយោគ ក៏ដូចគ្នាដែរ គឺថាអត្ថបទរបស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ មានន័យជ្រាលជ្រៅនិងច្បាស់លាស់ជាងអត្ថបទក្រោយៗទាំងអស់។

*ជារួម តាមការផ្ទៀងផ្ទាត់និងពិចារណាខាងលើ យើងគួររក្សាទំនុកដើម ព្រោះគ្មានអ្វីដែលគួរឱ្យកែលម្អ មួយវិញទៀត ការកែស្នាដៃដែលមានតម្លៃនិងមានភាពចំណាស់រួចហើយវាជាការមិនសូវល្អទេ គ្រាន់តែថា យើងអាចកែសម្រួលអក្ខរាវិរុទ្ធមួយចំនួនតាមសំណេរបច្ចុប្បន្ន ៕*

**សូមអរគុណ !**

# ឧបសម្ព័ន្ធ

១. ក្របសៀវភៅ "កម្រងសិល្បៈសិក្សា" (ឆ្នាំ១៩៥៨)



**២.** សេចក្ដី "ប្រកាស" របស់ក្រសួងសិក្សាធិការជាតិ ចំពោះសៀវភៅ "កម្រងសិល្បៈសិក្សា"



សៀវភៅ "កម្រងសិល្បៈសិក្សា" នេះកើតឡើងដោយការជួយយ៉ាងជ្រាលជ្រៅពីសំណាក់
"លី-គីមអួន" និង លោក "ឱណាស្សុ ហៅ សែម" ខាងការសរសេរជា "អក្សរក្មេង" និង ពេ
"ឃាខ្យ ឆន់ឃាត់" ខាងការជួយសរសេរទំនុកច្រៀង..។ ខ្ញុំសូមសម្ដែងសេចក្ដីអរគុណដោយស្មោះស្ម័គ្រ ឡុន-

# កម្រងសិល្បៈសិក្សា

ព.ស ២៥០១ គ.ស ១៩៥៩ បោះពុម្ពលើកទី២ រក្សាសិ

**ព្រះរាជអាណាចក្រ កម្ពុជា** **ប្រកាសក្រសួង**

អ្នកឧកញ៉ារដ្ឋលេខាធិការក្រសួងសិក្សាធិការជាតិ

លេខ៤៧៤៦ បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ ៤៤២ន.ស ចុះថ្ងៃទី ១០ កក្កដា ឆ្នាំ១៩៥៨ ស្ដីពីការតាំងគណៈរដ្ឋម

បានឃើញសេចក្ដីកត់ហេតុលេខ៦៧ ចុះថ្ងៃទី ០២ ធ្នូ ១៩៥៨ នៃគណៈកម្មការរៀងនៃបឋមសិ

ខ្មែរ ដែលតាំងដោយប្រកាសក្រសួងលេខ ១០០២ ចុះថ្ងៃទី ២២ មិនា ឆ្នាំ ១៩៥៨ ។

*តាមសេចក្ដីស្នើនៃនាយកសារធារណៈសិក្សា*

**សម្រេច :**

<u>ប្រការ ១</u>- សៀវភៅដែលមានចំណងជើង "កម្រងសិល្បៈសិក្សា" របស់លោក ឡុន-កន គ្រូបង្រៀន
នៅមន្ទីរចាត់ការនៃក្រសួងគរុកោសល្យភ្នំពេញ បានបញ្ចូលទៅក្នុងពពួកសៀវភៅនិងការផ្សាយខា
សិក្សា ដែលនឹងបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងសាលារៀនសាធារណៈទូទៅក្នុងព្រះរាជាណាចក្រ

<u>ប្រការ ២</u>- នាយខុទ្ទកាល័យនិងសាធារណៈសិក្សា ត្រូវទទួលភារៈចាត់តាមមុខក្រសួងរៀងខ្លួនដើម្បីឱ្យបានស
តាមប្រកាសក្រសួងនេះ ។

ភ្នំពេញនៅថ្ងៃទី ៩ ធ្នូ ១៩៥៨

ហត្ថលេខា ចៅ-សេង

贈 千代田区立富士見小学校
Presented by Fujimi Elementary School, JAPAN

៣. អក្សរភ្លេង បទ "សាវតារខ្មែរ" ក្នុងសៀវភៅ "កម្រងសិល្បៈសិក្សា"



៨. ទំនុកច្រៀង បទ "សារវ៉ាន់ខ្មែរ" ក្នុងសៀវភៅ "កម្រងសិល្បៈសិក្សា"

## សារវ៉ាន់ខ្មែរ

- [illegible]
- [illegible]

## សេចក្តីណែនាំ

[illegible]